## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ០៣៥៧ ព.ណ..ភណប

ថ្ងៃ អង្គារ ៥កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២១

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ហេង ខួន ខមតេនី**

**កម្មវត្ថុ:** លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការនាំចូល និងចែកចាយផលិតផលទុយោ និងទុយោទឹកម៉ាក VINACONEX ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ហេង ខួន ខមតេនី** ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៣៨៣៧៨/១១ ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងពាណិជ្ជកម្មសូមបញ្ជាក់ជូនលោក/លោកស្រីប្រធានជ្រាបថា តាមរយៈការចុះបញ្ជីម៉ាកដែលមានលេខចុះបញ្ជី KH/៣៨៣៧៨/១១ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនរបស់លោក/លោកស្រីបានទទួលសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ ក្នុងការផលិត នាំចូល ចែកចាយ ដាក់តាំង ឬផ្សព្វផ្សាយ ចំពោះទំនិញដែលជាកម្មវត្ថុនៃការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាស្វ័យប្រវត្តិ ដូចមានចែងក្នុងមាត្រា ៣ និងមាត្រា ១១ នៃច្បាប់ដែលបានយោងខាងលើនេះ។

លិខិតបញ្ជាក់នេះ មានសុពលភាពត្រឹមថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០២១ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវអស់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ក្នុងករណីដែលការចុះបញ្ជីម៉ាកត្រូវបានបាត់បង់សុពលភាពដោយប្រការណាមួយនោះ។

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតបញ្ជាក់នេះក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក ប្រជា**

*<u>ចម្លងជូន:</u>*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469